ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តរតនគិរី

## នាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តរតនគិរី

រឿងក្តីរដ្ឋប្បវេណីលេខ ១៧៤ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ ។

សញ្ញាណរឿងក្តី: **លែងលះ** ។

ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ។

សាលក្រមលេខ១០៤/២៣ (ខ)

ថ្ងៃប្រកាសសាលក្រម ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១ ។


## នាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តរតនគិរី


## ចេញសាលក្រមដែលមានខ្លឹមសារដូចតទៅ

<u>ដើមចោទ</u>៖ ឈ្មោះ [redacted] **គុយ** ភេទប្រុស អាយុ៥០ឆ្នាំ ជនជាតិខ្មែរ មុខរបរ លក់ដូរ មានទីលំនៅបច្ចុប្បន្ន [redacted]

<u>ចុងចម្លើយ</u>៖ ឈ្មោះ [redacted] **ឡេង** ភេទស្រី អាយុ៤១ឆ្នាំ ជនជាតិខ្មែរ មុខរបរ លក់ដូរ មានទីលំនៅបច្ចុប្បន្ន [redacted]

មេធាវីតំណាងដោយអាណត្តិ៖ លោកស្រី [redacted] មានការិយាល័យស្ថិតនៅ [redacted]

## អង្គហេតុ និងចំណុចវិវាទ

**១. ការទាមទាររបស់ដើមចោទ**

១.១ សុំផ្តាច់សមគ្គសង្វាសពីប្រពន្ធឈ្មោះ [redacted] ឡេង។

១.២ កូនមានចំនួន៣នាក់

ក-ឈ្មោះ [redacted] សុភាព ភេទប្រុស កើតថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៧។

ខ-ឈ្មោះ [redacted] សុភ័ណ្ឌ ភេទប្រុស កើតថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០០។

គ-ឈ្មោះ [redacted] សុភ័ក្ត្រ ភេទប្រុស កើតថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៥។

សុំសិទ្ធិគ្រប់គ្រង ចិញ្ចឹម បីបាច់ ថែរក្សារហូតដល់ធំពេញវ័យ និងទុកសិទ្ធិគ្រប់បែបយ៉ាងជូនភាគីប្រពន្ធ សម្រាប់សួរសុខទុក្ខកូនបានគ្រប់ពេលវេលា។



Scanned with CamScanner

១.៣ ទ្រព្យសម្បត្តិរួមមានដូចជា:

-ដីក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៦០២០២០៣-០១៥៦ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨ ស្ថិតនៅភូមិ៧មករា សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី។

-ដីក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៦០២០២០៥-០៥១០ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩ ស្ថិតនៅភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី។

-ឡាន ១គ្រឿង ម៉ាក Luxus470 សេរីឆ្នាំ២០០៣ ពណ៌កាម៉ៃ ពាក់ស្លាកលេខ ភ្នំពេញ ៩៨៩៧ ដើមចោទសុំសិទ្ធិគ្រប់គ្រង ចាត់ចែង កាត់ឈ្មោះ លក់ ផ្ទេរ ដាក់បញ្ចាំ ធ្វើមរតក ធ្វើអំណោយ បានគ្រប់ពេលវេលា ដោយមិនមានការពាក់ព័ន្ធនឹងភាគីប្រពន្ធ។

១.៤ បំណុលរួមមាន៖

-[redacted] ប្រហែលចំនួន ១៣០.០០០ដុល្លារអាមេរិក ដើមចោទសុខចិត្តទទួលរ៉ាប់រងសងម្នាក់ឯងមិនមានពាក់ព័ន្ធនឹងប្រពន្ធឡើយ។

**២.ការទាមទាររបស់ចុងចម្លើយក្នុងបណ្តឹងតប**

២.១ សុំផ្តាច់សមគ្គសង្វាសពីប្តីឈ្មោះ[redacted] កុយ

២.២ ស្នើសុំសិទ្ធិគ្រប់គ្រងកូនចំនួន២នាក់

ក-ឈ្មោះ [redacted] សុភ័ណ្ឌ ភេទប្រុស កើតថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០០។

ខ-ឈ្មោះ [redacted] សុភ័ក្ត ភេទប្រុស កើតថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៥។

២.៣ ស្នើសុំសិទ្ធិគ្រប់គ្រងចាត់ចែងនូវដី ទំហំ១៥ម៉ែត្រ បណ្តោយ២២ម៉ែត្រ ផ្ទះសំណាក់ពីលើ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៦០២០២០៣-០១៥៦ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨ ស្ថិតនៅភូមិ៧មករា សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី។

**៣.ការពន្យល់ត្រួសៗពីរឿងក្តី**

**២.១-** ដើមចោទ និងចុងចម្លើយបានរៀបការជាមួយគ្នាជាប្តីប្រពន្ធកាលពីឆ្នាំ១៩៩៥ ដោយមិនបានបញ្ជាក់ឬចុះសំបុត្រអាពាហ៍ពិពាហ៍អ្វីឡើយ។ រយៈពេលរួមរស់ជាមួយគ្នាមានកូនចំនួន៣នាក់ និងមានទ្រព្យសម្បត្តិរួមដូចក្នុងកម្មវត្ថុខាងលើ។ ការរួមរស់ជាមួយគ្នាមានសេចក្តីសុខជាធម្មតា តែពេលចុងក្រោយនេះនៅក្នុងគ្រួសារតែងតែមានបញ្ហាមិនឈប់ឈរ ដូចជាអត្តចរិក ពាក្យសម្តី ចិត្តគំនិត និងមិនមានការគោរពសិទ្ធិគ្នានោះឡើយ។ គូភាគីបានព្រមព្រៀងលែងលះគ្នានៅសាលាសង្កាត់ឡាបានសៀក ដោយបានធ្វើកិច្ចសន្យាត្រឹមត្រូវ និងមានការឯកភាពគ្នាយ៉ាងពិតប្រាកដដោយពុំមានការបង្ខិតបង្ខំពីបុគ្គលណាមួយឡើយ ប៉ុន្តែមកដល់ពេលនេះភាគីចុងចម្លើយពុំបានគោរព និងអនុវត្តតាមការព្រមព្រៀងគ្នានោះឡើយ។ ដើម្បីរក្សាផលប្រយោជន៍ស្របច្បាប់ និងជៀសវាងបញ្ហាផ្សេងៗដែលកើតមានឡើងតទៅទៀត ទើបដើមចោទដាក់ពាក្យបណ្តឹងមកតុលាការ។

**២.២- ចំណុចវិវាទ៖** ចុងចម្លើយបដិសេធលើការទាមទាររបស់ដើមចោទ ដោយសុំសិទ្ធិគ្រប់គ្រងកូន និងទ្រព្យសម្បត្តិរួមពាក់កណ្តាលម្នាក់។



Scanned with CamScanner

**២.៣- ការអះអាងរបស់ភាគី**

ក-<u>ដើមចោទធ្វើការអះអាងថា:</u> ខ្ញុំបាទស្នើសុំរក្សាការទាមទារដូចមានក្នុងពាក្យបណ្តឹងរបស់នាងខ្ញុំនៅដដែល មិនមានអ្វីកែប្រែនោះទេ។ ខ្ញុំមិនមានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ។ ចុងចម្លើយចុះចោលផ្ទះរយៈពេល ២ឆ្នាំហើយ។ ចំពោះទ្រព្យសម្បត្តិរួមដែលខ្ញុំបានបញ្ជាក់នោះ គឺជាទ្រព្យសម្បត្តិរួមគ្នាពីរនាក់ប្តីប្រពន្ធខ្ញុំ ហើយខ្ញុំសុំគ្រប់គ្រងចាត់ចែងម្នាក់ឯង ប៉ុន្តែឡាន ម៉ាក Luxus470 សេរីឆ្នាំ២០០៣ ខ្ញុំ និងចុងចម្លើយបានលក់ចេញបាត់ហើយតាំងពីឆ្នាំមុនម្ល៉េះ ហើយប្រាក់បានមកពីការលក់រថយន្តនោះ គឺចុងចម្លើយបានចាត់ចែងអស់ហើយ។ ប័ណ្ណកម្មសិទ្ធិដាក់បញ្ចាំនៅធនាគារ។ ក្នុងឆ្នាំ២០១៧ ខ្ញុំបានផ្តិតមេដៃលែងលះគ្នានៅសាលាសង្កាត់ឡាបានសៀក គឺចុងចម្លើយស្ម័គ្រចិត្តចិញ្ចឹមកូនទាំងបីនាក់ ប៉ុន្តែចុងចម្លើយមិនបានអនុវត្តតាមនោះទេ គឺបានទុកកូនឱ្យម្តាយរបស់គាត់មើលថែ ដល់ពេលកូនៗខ្ញុំប្រាប់ខ្ញុំទើបខ្ញុំដឹងរឿងដាក់ពាក្យសុំចូលមកតុលាការដើម្បីលែងលះ ហើយមិនព្រមឱ្យកូនទៅចុងចម្លើយចិញ្ចឹមមើលថែនោះទេ។ ចំពោះកូនប្រុសច្បងឈ្មោះ [redacted] សុភាព គាត់បានរៀបការរួចហើយ ចំណែកកូន២នាក់ទៀត ឈ្មោះ [redacted] សុភ័ណ្ឌ និងឈ្មោះ [redacted] សុភ័ក្ត ស្ថិតក្រោមការគ្រប់គ្រងមើលថែរបស់ខ្ញុំ ហើយពួកគេនៅបន្តរៀនសូត្រដដែរ។ កូនដែលមានអាយុក្រោម១៨ឆ្នាំ គឺឈ្មោះ [redacted] សុភ័ក្ត។ ខ្ញុំមិនទាមទារថ្លៃអាហារកាតព្វកិច្ចចិញ្ចឹមកូននោះទេ។ ចំពោះបំណុលខ្ញុំសងតែម្នាក់ឯងបាន។ ខ្ញុំបានផ្តិតមេដៃខ្ចីប្រាក់ធនាគារចំនួន ៣ម៉ឺនដុល្លារអាមេរិក គឺចុងចម្លើយជាអ្នកដកលុយយកទៅប្រើប្រាស់ ហើយខ្ញុំជាអ្នកចេញសងតែម្នាក់ឯង។ ម្យ៉ាងទៀត ពេលលក់ឡានចុងចម្លើយក៏បានដកយកលុយ ៥ពាន់ដុល្លារអាមេរិក ចំនួន២លើកផងដែរ។

ខ-<u>ចុងចម្លើយធ្វើការអះអាងថា:</u> កូនប្រុសច្បងរស់នៅបន្ទប់ជួល ខ្ញុំជាអ្នកចេញលុយថ្លៃជួលបន្ទប់ឱ្យ។ ចំពោះកូនពៅរស់នៅជាមួយដើមចោទ។ បំណុលធនាគារចំនួន ១៥០.០០០ដុល្លារអាមេរិក ខ្ញុំបានផ្តិតមេដៃមែន ប៉ុន្តែខ្ញុំមិនបានចាយនោះទេ។ ពេលលែងលះគ្នានៅសង្កាត់គឺពេលណាលក់ផ្ទះសំណាក់បាន គឺចែកខ្ញុំ ១០០.០០០ដុល្លារអាមេរិក សល់ប៉ុន្មានទុកឱ្យកូន។ ចំពោះបំណុលនៅសល់ ១៣០.០០០ ដុល្លារអាមេរិក។ ពេលលក់រថយន្តខ្ញុំមិនបានប្រើប្រាស់លុយបានពីការលក់រថយន្តនោះទេ។

គ-<u>មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទថ្លែងការណ៍ថា:</u> កូនក្តីខ្ញុំឯកភាពលើការផ្តាច់សមគ្គសង្វាស។ ចំពោះអំណាចមេបាកូនក្តីខ្ញុំសុខចិត្តប្រគល់សិទ្ធិឱ្យកូនសម្រេចចិត្ត ថាពួកគេចង់រស់នៅជាមួយអ្នកណា។ ចំពោះទ្រព្យសម្បត្តិរួមកូនក្តីខ្ញុំស្នើសុំបែងចែកដីម្នាក់មួយកន្លែង ដោយគាត់យកដីដែលមានឃ្លាំង នៅក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៦០២០២០៥-០៥១០ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩ ស្ថិតនៅភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី។ ចំណែកដីមួយកន្លែងទៀតដែលមានផ្ទះសំណាក់នៅពីលើ កូនក្តីខ្ញុំប្រគល់ឱ្យភាគីដើមចោទ។ ចំពោះបំណុលរួមជាង ១៣០.០០០ ដុល្លារអាមេរិក កូនក្តីខ្ញុំសុំរួមចំណែកសងបំណុលជំពាក់ចំនួន ៥០.០០០ ដុល្លារអាមេរិកទៅបំណុលទាំងអស់។ ទ្រព្យសម្បត្តិទាំងអស់គឺរកបានជាមួយគ្នា ដូច្នេះគប្បីបែងចែងឱ្យមានចំណែករបស់កូនក្តីខ្ញុំផងដែរ ដើម្បីបានចំណែកស្មើគ្នា។ សូម្បីបំណុលក៏កូនក្តីខ្ញុំសុខចិត្តជួយចេញសងចំនួន ៥០.០០០ ដុល្លារអាមេរិក ដោយសារបំណុលនោះដើមចោទជាអ្នកខ្ចីចាត់ចែងតែម្នាក់ឯងប៉ុណ្ណោះ។ ដូច្នេះក្នុងនាមខ្ញុំជាមេធាវីតំណាងដោយអាណត្តិឱ្យកូនក្តីខ្ញុំ នាងខ្ញុំស្នើសុំតុលាការសម្រេចដូចការទាមទាររបស់កូនក្តីរបស់ខ្ញុំ។

**២.៤-** ដើមចោទឱ្យតុលាការធ្វើការពិនិត្យភស្តុតាងជាឯកសារមានដូចខាងក្រោម៖



Scanned with CamScanner

-សៀវភៅគ្រួសារលេខ ២០២៣៣ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៥។

-សៀវភៅស្នាក់នៅលេខ ១១២២៨៤ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៩។

-សំបុត្របញ្ជាក់កំណើត លេខ ១៣៤០ ចុះថ្ងៃទី១៧ វិច្ឆិកា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] សុភាព។

-សំបុត្របញ្ជាក់កំណើត លេខ ១៣៤១ ចុះថ្ងៃទី១៧ វិច្ឆិកា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] សុភ័ណ្ឌ។

-សំបុត្របញ្ជាក់កំណើត លេខ ០៩ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] សុភ័ក្ត។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៦០២០២០៣-០១៥៦ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៦០២០២០៥-០៥១០ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩

-កំណត់ហេតុផ្សះផ្សាសម្រុះសម្រួល ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាសង្កាត់ឡាបានសៀក

-ឯកសាររបស់ធនាគាកាណាឌីយ៉ា ចំនួន៥សន្លឹក (ថតចម្លង)។

## សំអាងហេតុ

**តាមលទ្ធផលនៃការសាកសួរភាគី និងពិនិត្យភស្តុតាង**

**ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា:**

១. សាលាដំបូងខេត្តរតនគិរី មានសមត្ថកិច្ចទទួលពាក្យបណ្តឹងរបស់ដើមចោទ និងវិនិច្ឆ័យលើរឿងក្តីនេះស្របតាមក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

២. ដើមចោទឈ្មោះ [redacted] កុយ និងចុងចម្លើយឈ្មោះ [redacted] ឡេង ពិតជាបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាត្រឹមត្រូវតាមប្រពៃណី ប៉ុន្តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ ឱ្យបានត្រឹមត្រូវតាមច្បាប់នោះឡើយ ។

៣. ក្រោយពេលរៀបអាពាហ៍ពិពាហ៍បានជាច្រើនឆ្នាំ គូភាគីពិតជារស់នៅមិនចុះសម្រុះនឹងគ្នានោះទេ ដែលធ្វើឱ្យភាគីអស់មនោសញ្ចេតនារស់នៅជាមួយគ្នាប្រាកដមែន ។

៤. ដើមចោទ និងចុងចម្លើយរួមរស់ជាមួយគ្នាមានទ្រព្យសម្បត្តិរួមមួយចំនួនដូចជា៖

-ដីក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៦០២០២០៣-០១៥៦ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨ ស្ថិតនៅភូមិ៧មករា សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី។

-ដីក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៦០២០២០៥-០៥១០ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩ ស្ថិតនៅភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី។

-ឡាន ១គ្រឿង ម៉ាក Luxus470 សេរីឆ្នាំ២០០៣ ពណ៌កាម៉ែ ពាក់ស្លាកលេខ ភ្នំពេញ ៩៨៩៧។ ប៉ុន្តែគូភាគីបានអះអាងថា ឡាននេះបានលក់រួចហើយ ដូច្នេះតុលាការមិនពិចារណាសម្រេចឡើយ។

៥. ភាគីដើមចោទបានធ្វើការអះអាងថា ចុងចម្លើយមិនបានអនុវត្តតាមកំណត់ហេតុផ្សះផ្សាសម្របសម្រួលនៅសាលាសង្កាត់ឡាបានសៀកនោះទេ ដូច្នេះខ្លួនសុំសិទ្ធិអំណាចមេបាលើកូន និងគ្រប់គ្រងទ្រព្យសម្បត្តិរួមដែលមានទាំងអស់ទុកឱ្យកូន ព្រមទាំងបំណុលធនាគារផងដែរ គឺខ្លួនជាអ្នករ៉ាប់រងម្នាក់ឯង។

៦. ចុងចម្លើយបានដាក់បណ្តឹងតប និងធ្វើការអះអាងថា ខ្លួនពិតជាបានខ្ចីតមេដៃខ្ចីប្រាក់ពីធនាគារមែន ដូច្នេះខ្លួនរួមចំណែកចេញសងបំណុលដែលនៅសល់ ចំនួន៥០.០០០ដុល្លារអាមេរិក និងទាមទារដីក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៦០២០២០៥-០៥១០ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩ មកគ្រប់គ្រង។



Scanned with CamScanner

៧.តាមកំណត់ហេតុផ្សះផ្សាសម្រុះសម្រួល ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៧ របស់គណៈកម្មការធិការដោះស្រាយទំនាស់ នៃសាលាសង្កាត់ឡាបានសៀក តុលាការនឹងពិចារណា។ ពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរួម គឺគូភាគីពិតជាបានអះអាងថា រកបានជាមួយគ្នាក្នុងអំឡុងពេលរស់នៅជាប្តីប្រពន្ធនឹងគ្នាប្រាកដមែន។ ហេតុនេះគប្បីតុលាការធ្វើការបែងចែកទៅតាមការពិចារណា និងពិនិត្យជាក់ស្តែង ដើម្បីការពារផលប្រយោជន៍ និងសិទ្ធិរបស់គូភាគីទាំងពីរ។

៨.ចំពោះបំណុលរបស់ធនាគារកាណាឌីយ៉ា ប្រហែល ១៣០.០០០ (ដប់បីម៉ឺន) ដុល្លារអាមេរិក ជាកាតព្វកិច្ចរបស់គូភាគីក្នុងការអនុវត្តរួមគ្នា ដូច្នេះតុលាការមិនលើកយកមកពិចារណាសម្រេចឡើយ។

៩. តាមការអះអាងរបស់គូភាគី ក្នុងអំឡុងពេលរួមរស់ជាប្តីប្រពន្ធនឹងគ្នាមាន កូនចំនួន៣នាក់៖

-ឈ្មោះ [redacted] សុភាព ភេទប្រុស កើតថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៧។

-ឈ្មោះ [redacted] សុភ័ណ្ឌ ភេទប្រុស កើតថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០០។

-ឈ្មោះ [redacted] សុភ័ក្ត ភេទប្រុស កើតថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៥។

តុលាការយល់ឃើញថាឈ្មោះ [redacted] សុភាព និងឈ្មោះ [redacted] សុភ័ណ្ឌ មាននីតិភាពរួចហើយ អាចធ្វើការសម្រេចចិត្តដោយខ្លួនឯងបានហើយ ដូច្នេះតុលាការមិនពិចារណាសម្រេចបែងចែកឡើយ។ ចំណែកឈ្មោះ [redacted] សុភ័ក្ត បច្ចុប្បន្នរស់នៅជាមួយប្តីឈ្មោះ [redacted] កុយ ដូច្នេះតុលាការសម្រេចកំណត់យកឈ្មោះ [redacted] កុយ ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] សុភ័ក្ត។

១០. ការលើកឡើងរបស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានថ្លែងការណ៍ថា ស្នើសុំឱ្យតុលាការសម្រេចតាមការទាមទាររបស់កូនក្តី។ តុលាការនឹងពិចារណា។

១១. គូភាគីរៀបអាពាហ៍ពិពាហ៍ ពុំមានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ គប្បីតុលាការសម្រេចលើកចោលតាមបញ្ញត្តិមាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

១២. ដើមចោទជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី តាមបញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្តីសម្រេចបញ្ចប់

១. ច្រានចោលពាក្យសុំដែលដើមចោទទាមទារផ្តាច់សមគ្គសង្វាសពីប្រពន្ធ តាមបញ្ញត្តិមាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២. កំណត់យកឈ្មោះ [redacted] កុយ ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] សុភ័ក្ត ភេទប្រុស កើតថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៥។

-ភាគីដែលពុំមានអំណាចមេបា មានសិទ្ធិចូលជួប និងប្រាស្រ័យ ទាក់ទងជាមួយ កូនបាន។ រីឯ ភាគីដែលមានអំណាចមេបាត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ភាគីម្ខាងទៀត យោងតាមមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី ។

៣. បែងចែកទ្រព្យសម្បត្តិរួមដូចខាងក្រោម៖

ក-ដីក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៦០២០២០៣-០១៥៦ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨ ស្ថិតនៅភូមិ៧មករា សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ប្រគល់ឱ្យទៅឈ្មោះ [redacted] កុយ ជាម្ចាស់កម្មសិទ្ធិ



Scanned with CamScanner

ខ-ដីក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៦០២០២០៥-០៥១០ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩ ស្ថិតនៅភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ប្រគល់ឱ្យទៅឈ្មោះ [redacted] ឡេង ជាម្ចាស់កម្មសិទ្ធិ

ចំពោះការទាមទារលើសពីនេះច្រានចោល។

៤. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា** [redacted]

---

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ សុក្រ ៤រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រតនគិរី ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]